# ពេលយើងឃ្លាតចេញពីគ្នា

ប្រធាន ថូម៉ាស អេស ម៉នសុន

*គ្មានយើងណាម្នាក់អាចគិតឃើញពីសារៈសំខាន់ដ៏ពេញលេញនៃអ្វីដែលព្រះគ្រីស្ទបានធ្វើសម្រាប់យើងក្នុងសួនច្បារ គេតសាម៉ានី ឡើយ តែខ្ញុំមានអំណរគុណជារៀងរាល់ថ្ងៃក្នុងជីវិតខ្ញុំចំពោះការពលិកម្មដែលធ្វើឲ្យធួនរបស់ទ្រង់ ។*

បងប្អូនប្រុសស្រីទាំងឡាយ ដួងចិត្តខ្ញុំបានស្កប់ស្កល់ ពេលយើងបានមកដល់ចុងបញ្ចប់នៃសន្និសីទនេះ ។ យើងមានអារម្មណ៍ពីព្រះវិញ្ញាណនៃព្រះអម្ចាស់យ៉ាងបរិបូរណ៍ ។ ខ្ញុំសូមសម្ដែងអំណរគុណរបស់ខ្ញុំចំពោះសមាជិកសាសនាចក្រគ្រប់ទិសទីដែលបានចូលរួម ព្រមទាំងអ្នកដែលបានអធិស្ឋានផងដែរ ។សូមឲ្យយើងចងចាំជានិច្ចពីសារលិខិតដែលយើងបានឮ ។ ពេលយើងទទួលទស្សនាវដ្ដី *Ensign* និង *លីអាហូណា* ដែលនឹងមាននូវសារលិខិតទាំងនេះជាអក្សរ សូមឲ្យយើងអាចអានហើយសិក្សាពាក្យពេចន៍ទាំងនោះ ។

ជាថ្មីម្ដងទៀត តន្ត្រីនៅគ្រប់សម័យប្រជុំគឺមានភាពពីរោះរណ្ដំណាស់ ។ ខ្ញុំសូមសម្ដែងនូវអំណរគុណរបស់ខ្ញុំផ្ទាល់ដល់អ្នកដែលមានឆន្ទៈដើម្បីចែកចាយទេពកោសល្យរបស់គេជាមួយនឹងយើង និងអ្នកដែលបានបំផុសគំនិតយើងក្នុងដំណើរការនេះ ។

យើងបានលើកដៃគាំទ្រ ដល់បងប្អូនប្រុសដែលត្រូវបានហៅសម្រាប់តួនាទីថ្មីអំឡុងពេលនៃសន្និសីទនេះ ។ យើងចង់ឲ្យពួកគេដឹងថា យើងរំពឹងទុកក្នុងការធ្វើការជាមួយនឹងពួកគេក្នុងកិច្ចការរបស់លោកថៅហ្វាយ ។

ខ្ញុំសូមសម្ដែងក្ដីស្រឡាញ់និងការដឹងគុណរបស់ខ្ញុំចំពោះទីប្រឹក្សារបស់ខ្ញុំ គឺប្រធាន ហិនរី បី អាវរិង និងប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ។ ពួកលោកគឺជាបុរសដែលមានប្រាជ្ញានិងការយល់ដឹង ។ ការបម្រើរបស់ពួកលោកគឺមានតម្លៃលើសលុប ។ ខ្ញុំស្រឡាញ់ហើយគាំទ្រដល់បងប្អូនប្រុសរបស់ខ្ញុំក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ពួកលោកបម្រើបានប្រពៃបំផុត ហើយពួកលោកមានការលះបង់ខ្ពស់ចំពោះកិច្ចការនេះ ។ ខ្ញុំក៏សូមសម្ដែងក្ដីស្រឡាញ់របស់ខ្ញុំដល់សមាជិកនៃពួកចិតសិបនាក់ និងគណៈប៊ីស្សពជាអធិបតីផងដែរ ។

យើងជួបនូវបញ្ហាជាច្រើនក្នុងពិភពលោកសព្វថ្ងៃនេះ តែខ្ញុំសូមអះអាងដល់អ្នកថា ព្រះវរបិតាសួគ៌យើងទ្រង់ខ្វល់ព្រះទ័យចំពោះយើង ។ ទ្រង់ស្រឡាញ់យើងម្នាក់ៗ ហើយទ្រង់នឹងប្រទានពរដល់យើង ពេលយើងស្វែងរកទ្រង់តាមរយៈការអធិស្ឋាន ហើយព្យាយាមគោរពតាមព្រះបញ្ញត្តិទ្រង់នោះ ។

យើងជាសាសនាចក្រមួយដែលមានលក្ខណៈជាសាកល ។ សមាជិកភាពរបស់យើងគឺមាននៅជុំវិញពិភពលោក ។ សូមឲ្យយើងធ្វើជាពលរដ្ឋល្អរបស់ប្រទេសជាតិ ដែលយើងរស់នៅ និងធ្វើជាអ្នកជិតខាងដ៏ល្អក្នុងសហគមន៍យើង ដោយឈោងជួយដល់មនុស្សនៃសាសនាដទៃ ក៏ដូចជាសមាជិករបស់យើងផងដែរ ។ សូមឲ្យយើងធ្វើជាគំរូនៃភាពស្មោះត្រង់ និងសច្ចធម៌នៅគ្រប់ទីកន្លែងដែលយើងទៅ និងនៅក្នុងអ្វីៗដែលយើងធ្វើ ។

បងប្អូនប្រុសស្រីទាំងឡាយ សូមអរគុណចំពោះការអធិស្ឋានរបស់អ្នកសម្រាប់ខ្ញុំ និងសម្រាប់ពួកអ្នកមានសិទ្ធិអំណាចទូទៅក្នុងសាសនាចក្រនេះ ។ យើងមានអំណរគុណជាខ្លាំងចំពោះអ្នក និងអ្វីៗទាំងអស់ដែលអ្នកធ្វើដើម្បីជួយជំរុញដល់កិច្ចការនៃព្រះអម្ចាស់ ។

ពេលអ្នកត្រឡប់ទៅផ្ទះអ្នកវិញ សូមឲ្យអ្នកប្រកបដោយសុខសុវត្ថិភាព ។ សូមឲ្យពរជ័យនៃស្ថានសួគ៌បានស្រោចស្រប់មកលើអ្នកគ្រប់គ្នា ។

ឥឡូវពីមុនយើងបញ្ចប់នៅថ្ងៃនេះ ខ្ញុំសូមចែកចាយនឹងអ្នកពីក្ដីស្រឡាញ់របស់ខ្ញុំចំពោះព្រះអង្គសង្គ្រោះ និងចំពោះការពលិកម្មដែលធ្វើឲ្យធួនដ៏ធំធេងរបស់ទ្រង់សម្រាប់យើង ។ ក្នុងរយៈពេលបីសប្ដាហ៍ពួកគ្រីស្ទានក្នុងពិភពលោកទាំងមូលនឹងប្រារព្ធបុណ្យ អ៊ីស្ទើរ ។ ខ្ញុំជឿជាក់ថា គ្មានយើងណាម្នាក់អាចគិតឃើញពីសារៈសំខាន់ដ៏ពេញលេញនៃអ្វីដែលព្រះគ្រីស្ទបានធ្វើសម្រាប់យើងក្នុងសួនច្បារ គេតសាម៉ានី ឡើយ តែខ្ញុំមានអំណរគុណជារៀងរាល់ថ្ងៃក្នុងជីវិតខ្ញុំចំពោះការពលិកម្មដែលធ្វើឲ្យធួនរបស់ទ្រង់សម្រាប់យើងនោះ ។

នៅគ្រាចុងក្រោយ ទ្រង់អាចនឹងគេចចេញបាន ។ តែទ្រង់មិនបានធ្វើដូច្នោះឡើយ ។ ទ្រង់បានឆ្លងកាត់គ្រប់ទាំងអស់ ដើម្បីទ្រង់អាចសង្គ្រោះអ្វីៗគ្រប់យ៉ាង ។ ក្នុងការធ្វើដូច្នោះ ទ្រង់បានប្រទានជីវិតដល់យើងដែលហួសពីជីវិតរមែងស្លាប់នេះ ។ ទ្រង់បានសង្គ្រោះយើងចេញពីការធ្លាក់របស់អ័ដាម ។

ខ្ញុំមានអំណរគុណចំពោះទ្រង់អស់ពីដួងចិត្តខ្ញុំ ។ ទ្រង់បានបង្រៀនយើងពីរបៀបរស់នៅ ។ ទ្រង់បានការពារដល់ការសង្គ្រោះរបស់យើង ។

ជាចុងបញ្ចប់ ខ្ញុំសូមចែកចាយនឹងអ្នកនូវពាក្យដ៏មានន័យ ដែលនិពន្ធដោយ អិមីលី ហារីស ដោយរៀបរាប់បានយ៉ាងល្អពីអារម្មណ៍ខ្ញុំពេលបុណ្យ អ៊ីស្ទើរ បានចូលមកដល់ ៖

*ក្រណាត់ដែលបានរុំទ្រង់គឺនៅទទេស្អាត ។*
*វាត្រូវបានទុកចោលនៅទីនោះ*
*នៅថ្មី ហើយសស្អាត ។*
*ទ្វារផ្នូរបានបើកចំហចោល ។*
*ថ្មត្រូវបានរំកិលចេញ*
*ហើយខ្ញុំស្ទើរតែឮពួកទេវតាច្រៀងសរសើរទ្រង់ ។*
*ក្រណាត់មិនអាចរុំទ្រង់ជាប់ឡើយ ។*
*ថ្មមិនអាចឃុំទុកទ្រង់បានឡើយ ។*
*មានសម្លេងជាច្រើនបានបន្លឺកាត់រូងថ្មទទេស្អាតនោះថា*
*« ទ្រង់មិនគង់នៅទីនេះទេ » ។*
*ក្រណាត់ដែលធ្លាប់រុំទ្រង់ឥឡូវនៅទទេ ។*
*វាត្រូវបានទុកចោល*
*នៅថ្មី ហើយសស្អាត*
*អូ អាឡេលូយ៉ា វានៅទទេស្អាត ។*

បងប្អូនប្រុសស្រីទាំងឡាយរបស់ខ្ញុំ សូមពរជ័យកើតមានដល់អ្នក ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។